# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៥១

បន្ទាប់ពីវិលត្រឡប់ពីការឈប់សម្រាកអបអរពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ អស់រយៈពេលមួយសប្តាហ៍មក អង្គជំនុំជម្រះសាលាដំបូងបានផ្តើមការប្រជុំគ្នាសាជាថ្មីម្តងទៀតនាសប្តាហ៍នេះ ដើម្បីស្តាប់សក្ខីកម្មស្តីពីមន្ទីរសន្តិសុខ ស-២១ ជាលើកដំបូងក្នុងសំណុំរឿង០០២ វគ្គ២។[1] មន្ទីរសន្តិសុខ ស-២១ ដែលត្រូវបានស្គាល់ផងដែរថាជា គុកទួលស្លែង គឺធ្លាប់ជាទីតាំងឧក្រិដ្ឋកម្មដ៏សំខាន់ក្នុងសំណុំរឿង០០១ ដែលជាសវនាការជំនុំជម្រះក្តីរបស់លោក **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច** ដែលជាប្រធានគុកនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កន្លងទៅ គាត់ក៏ត្រូវបានអង្គជំនុំជម្រះសាលាដំបូងបានរកឃើញពិរុទ្ធភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។[2] បុគ្គលដែលបានផ្តល់សក្ខីកម្មដំបូងគេនាសប្តាហ៍នេះ គឺជាដើមបណ្តឹងរដ្ឋប្បវេណីលោក **ជុំ ម៉ី** ដែលជាអ្នករស់រាន

---

[1] សម្រាប់បទចោទពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ *សូមមើល* ដីកាដំណោះស្រាយនៃសំណុំរឿង០០២ វាក្យខណ្ឌ ៤១៥ដល់៤៧៤។

[2] លោក **កាំង ហ្គេចអ៊ាវ** (ហៅ **ឌុច**) ត្រូវបានរកឃើញពីពិរុទ្ធភាពដោយអង្គជំនុំជម្រះសាលាដំបូង ហើយត្រូវបានកាត់ទោសដាក់ពន្ធនាគារចំនួន ៣៥ឆ្នាំ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ *សូមមើល* “សាលក្រម” របស់អង្គជំនុំជម្រះសាលាដំបូង (ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០) លេខ E188 ។ លោក **កាំង ហ្គេចអ៊ាវ** បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ ទៅអង្គជំនុំជម្រះតុលាការកំពូល តែត្រូវបានច្រានចោលលើបណ្តឹងសាទុក្ខរបស់គាត់។ ការិយាល័យសហព្រះរាជអាជ្ញា ក៏បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះផងដែរ ហើយកាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយបានបង្កើនការដាក់ពន្ធធនាគារលើពិរុទ្ធជនរូបនេះទៅដល់ការជាប់គុកអស់មួយជីវិត *សូមមើល* “សាលដីកាបណ្តឹងសាទុក្ខ” របស់អង្គជំនុំជម្រះតុលាការកំពូល (ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២) លេខ F28។

មានជីវិតម្នាក់ក្នុងចំណោមគ្នាប្រាំពីរនាក់ ដែលបានរស់រានមានជីវិតពីការជាប់គុកនៅទួលស្លែង។ លោក **ជុំ ម៉ី** បាននិយាយយ៉ាងស៊ីជម្រៅពីការឈឺចាប់ដែលគាត់ធ្លាប់បានទទួលរងគ្រោះនៅក្នុងមន្ទីរសន្តិសុខនេះ និងការឈឺចាប់អស់រយៈពេលជាច្រើនឆ្នាំចាប់តាំងពីពេលដែលរូបគាត់បានជាប់គុក រហូតមកដល់ពេលបច្ចុប្បន្ន។ បុគ្គលដែលបានផ្តល់សក្ខីកម្មបន្ទាប់នោះ គឺជាសាក្សីលោក **ញ៉ែម អេន** បានផ្តល់សក្ខីកម្មស្តីពីការបំពេញការងារជាអ្នកថតរូបនៅក្នុងមន្ទីរសន្តិសុខ ស-២១ នេះ នៅខណៈពេលដែលគាត់បានកំពុងមានវ័យជំទង់។ គាត់បានពិពណ៌នាពីកិច្ចប្រជុំ និងការថតរូបរបស់សមាជិកសំខាន់ៗជាច្រើនរបស់បក្សកុម្មុយនីស្តកម្ពុជា និងការធ្វើដំណើរជុំវិញប្រទេសដើម្បីថតរូបអាងទំនប់ទឹក និងការដ្ឋាននានាផងដែរ។ បុគ្គលទីបីដែលបានផ្តល់សក្ខីកម្មនាសប្តាហ៍នេះ គឺលោក **តយ តេង** ជាអតីតអ្នកយាមនៅជើងឯក ដែលជាទីតាំងសម្លាប់មនុស្ស មានចម្ងាយប្រមាណ ១៥គីឡូម៉ែត្រនៅខាងក្រៅទីក្រុងភ្នំពេញ។[3] លោក **តយ តេង** បានផ្តល់សក្ខីកម្មនៅក្រោមវិធានការណ៍ការពារ ដោយបានបំលែងរូប និងសំឡេងរបស់គាត់។[4] នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង ក៏បានលើកឡើងពីបញ្ហាជាច្រើនពាក់ព័ន្ធនឹងបញ្ហានីតិវិធី និងផ្លូវច្បាប់ រួមមាន៖ ការប្រើប្រាស់ចម្លើយសារភាពក្នុងអំឡុងពេលនៃការតាំងសំណួរដេញដោល និងទំនាស់ផលប្រយោជន៍ដែលអាចនឹងកើតមានប្រឈមទៅនឹងលោកមេធាវី **គង់ សំអុន** ដែលជាមេធាវីជាតិការពារក្តីឲ្យជនជាប់ចោទលោក **ខៀវ សំផន**។

[3] ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច** បានជ្រើសរើសទីតាំងជើងឯក ជាទីតាំងសម្រាប់សម្លាប់មនុស្ស និងកប់សាកសព សម្រាប់អ្នកទោសដែលត្រូវបានដឹកជញ្ជូនពីមន្ទីរ ស-២១ និង ស-២៤ ហើយត្រូវបានសម្លាប់ភ្លាមៗនៅនឹងកន្លែងនោះតែម្តង *សូមមើល* “សាលក្រម” របស់អង្គជំនុំជម្រះសាលាដំបូង (ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០) លេខ E188 វាក្យខណ្ឌ ១៨៤ដល់១៨៩។

[4] វិធានការណ៍ការពារទាំងនេះ អនុលោមតាមវិធាន២៩ នៃវិធានផ្ទៃក្នុង និងបានបញ្ញត្តិផងដែរពីការរក្សាទុកអាសយដ្ឋាន និងព័ត៌មានលម្អិតរបស់សាក្សី ទាក់ទងនឹងភាពសម្ងាត់របស់សមាជិកនៃគ្រួសាររបស់សាក្សីផងដែរ *សូមមើល* វិសោធនកម្មលើកទី៩ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ចុះថ្ងៃទិ១៦ ខែមករា ឆ្នាំ២០១៥)។

* របាយការណ៍នេះ ត្រូវបានសរសេរដោយ លេណា ហារីស ពោមីរ៉យ (Lena Harris-Pomeroy), ម៉ាលេនី ហៃដ៍ (Melanie Hyde), ដាញ៉ែល ម៉ាតើស (Daniel Matters), នីកូឡាស មេយខក (Nicholas Maycock), ខេតលីន កាហ្វ្រៀ (Caitlin McCaffrie), តាយ លីណា និង ធន ស្ថាពរ ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូលូលូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដាសម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University